# ទស្សនវិទូ ប្លាតុង



.......................លោកគ្រូ ប្លាតុង និង សិស្ស អារីស្តូត.........................

....................... ប្លាតុង (៤២៨ – ៣៤៧ មុន គ.ស)........................ប្លាតុងមានឪពុកឈ្មោះ Ariston និងម្តាយឈ្មោះPérictioné។ លោកជាអ្នកក្រុងអាតែន។ម្តាយរបស់លោកជាប់ខ្សែញាតិជាមួយ Solon,អ្នកតែងច្បាប់និងតែងកំណាព្យដ៏ល្បីម្នាក់ជាប់នាមក្នុងបណ្តាបណ្ឌិតទាំងប្រាំពីររបស់ប្រទេសក្រិក។បណ្ឌិតSolonមានបងប្រុសឈ្មោះDropidesដែលបង្កើតជាបន្តបន្ទាប់Callaischosហើយ Critias ដែលបានធ្វើជាចៅក្រមក្នុងបណ្តាចៅក្រមទាំងសាបសិបហៅថាTrentes,និងGlaucon បន្តមកទៀតCharmide និង Périctioné ដែលបានរៀបការជាមួយAristonហើយបង្កើត Platon មកក្នុងជំនាន់ទី៦រាប់បន្តពីSolon។ចំណែកឯឪពុក របស់Platonវិញ,ពួគេថាតវង្សត្រកូលពីCodrusដែលជាកូនរបស់MélanthosដែលThrasylosជាអ្នកប្រវត្តិសាស្រ្តបានប្រាប់ថាជាកូនចៅរបស់អាទិទេពPoseidon។ Speusippe នៅក្នុងសៀវភៅ Le banquet dePlaton, Cléarque នៅក្នុងសៀវភៅ Éloge de Platon ហើយនិងAnaxilédès ក្នុងសៀវភៅTraité de la philosophie ភាគពីរបាននិយាយរៀបរាប់រឿងមួយដែលឮពេញក្រុងអាតែនថា៖កាលពី Perictioné ទើបធំពេញវ័យក្រមុំ,Aristonចង់ចាប់រំលោភ ប៉ុន្តែក៏បានឃើញមុខអាទិទេព Apollonចេញមកជួយសង្គ្រោះ Périctioné ហើយថែរក្សានាងអោយនៅព្រហ្មចារីរហូតទាល់ដល់ពេលសំរាលកូនប្លាតុងមកនៅថ្ងៃទី៧ ឧសភាជាថ្ងៃខួបកំណើតរបស់Apollonនៅឯក្រុងDelphes។Hermippe និយាយថា ប្លាតុង បានទទួលមរណភាពក្នុងពិធីជប់លៀងអាពាហ៍ពិពាហ៍មួយក្នុងជន្មាយុ៨១ឆ្នាំ។ក្នុងពេលកំពុងប្រលងប្រជែងការនិពន្ធ រឿងផ្នែកសោកនាដកម្ម,ស្រាប់តែប្លាតុងបានជួបសូក្រាតនៅខាងមុខរោងល្ខោន Dionysos ហើយក្រោយពីបានសំណេះសំណាលគ្នានោះមក,ប្លាតុងក៏បានដុតចោលរឿងនិពន្ធទាំងអស់ដែលលោកបានសរសេរ ដោយនិយាយឡើងថា៖ Hephaisto ឯងមកទីនេះមក!ប្លាតុងឥឡូវនេះត្រូវការឯង។ចាប់តាំងពីកាលនោះមកគឺនៅអាយុ២០ឆ្នាំ,ប្លាតុងក៏បានក្លាយខ្លួនជាសាវ័ករបស់សូក្រាត។ ប្លាតុងក្នុងទ្រឹស្តីអំពីគំនិតបាននិយាយ ថា៖បើសិនសតិចងចាំមានមែន,នោះក៏មកពីតែមានគំនិតក្នុងវត្ថុពិត ដោយសារថាសតិចងចាំគឺជាសតិចងចាំអំពីអ្វីមួយដែលនៅនឹង(មិនកំរើកឬគ្មានចលនា) ហើយដែលមាននៅតទៅហើយថាមានតែគំនិតទេដែលស្ថិតនៅនឹង(សំរាក)។ យុត្តិធម៌,ការប្រុងប្រយ័ត្ន,សេចក្តីក្លាហាននិងគតិបណ្ឌិតគឺជាទ្រព្យសម្បត្តិរបស់ព្រលឹង ; សម្ផស្សស្អាត,រូបរាងល្អ,សុខភាពល្អ និងកំលាំងកាយគឺជាទ្រព្យសម្បត្តិរបស់ខ្លួនប្រាណ; មិត្តភក្តិ,សុភមង្គលនៃមាតុភូមិ,ភាពសំបូររុងរឿងគឺជាទ្រព្យសម្បត្តិខាងក្រៅ។ពេលវេលាគឺជារូបភាពនៃអនន្តកាល ហើយមាននៅជានិច្ចជាកាលតទៅគ្មានទីបញ្ចប់។ពេលវេលាគឺជាចលនាមេឃព្រោះថាយប់,ថ្ងៃនិងខែ។ល។ គឺជាចំណែករបស់ពេលវេលា។ដូច្នេះអ្នកណាដែលលុបបំបាត់ការបង្កើតពិភពលោកបានក៏លុបបំបាត់ពេលវេលាបានដែរ។ចាប់តាំងពីពិភពលោកត្រូវបានបង្កើតមក,ពេលវេលាក៏កើតមានឡើង។បន្ទាប់ពីពេលវេលាកើតមានហើយ,ព្រះអាទិត្យ,ព្រះចន្ទនិងភពនៃប្រព័ន្ធព្រះអាទិត្យទាំងអស់ត្រូវបានកកើតឡើងដែរ។ដើម្បីអោយសត្វលោកបានស្គាល់ចំនួនម៉ោងនិងចំនួនលេខ ទើបព្រះបានផ្តល់ពន្លឺព្រះអាទិត្យអោយ ពួកគេ។មានមិត្តភាពបីប្រភេទគឺ៖

១_មិត្តភាពដែលកើតមកមានពីធម្មជាតិ
២_មិត្តភាពដែលកើតមកមានពីសង្គម
៣_មិត្តភាពដែលកើតមានមកពីការទទួលអោយស្នាក់នៅ

មិត្តភាពប្រភេទទីមួយគឺជាមិត្តភាពដែលកើតមានរវាងឪពុកម្តាយនិងកូន។គឺជាមិត្តភាពដែលគ្រប់សត្វលោកចូលរួមចំណែក។ មិត្តភាពប្រភេទទីពីរគឺជាមិត្តភាពសង្គមដែលកើតមកពីការជួបជុំគ្នា ការទៅលេងគ្នាទៅវិញទៅមកដោយគ្មានជាប់សាច់ញាតិគ្នានឹងគ្នា។រីឯមិត្តភាពប្រភេទទីបីគឺជាមិត្តភាពដែលកើតមានឡើងពីការទទួលអោយស្នាក់នៅដល់អ្នកដែលមិនស្គាល់មកពីទីឆ្ងាយ។ជួនកាលគេបន្ថែមប្រភេទមិត្តភាពមួយទៀតជាមិត្តភាពទីបួនគឺមិត្តភាពនៃសេចក្តីស្រលាញ់។